# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
## ការិយាល័យផ្នែក ចុះឈ្មោះ និង ចាត់តាំង សិស្ស
## វិធីជ្រើសរើសសាលា សម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦
បញ្ជីផ្ទៀងផ្ទាត់សម្រាប់សិស្សដែលជាសិស្សរបស់ក្រសួងអប់រំ

*ត្រៀមខ្លួនជាមុន*



✓ ពិនិត្យមើលរបាយការណ៍សិក្សានៃឆ្នាំដែលសិស្សទើបនឹងរៀនចប់ថ្មីៗ។ នេះរួមមាន ប៉ុន្តែគ្មានកំណត់ដូចជា ពិន្ទុ វត្តមានអវត្តមាន អាកប្បកិរិយា និង លទ្ធផលនៃការប្រឡងទូទៅ។

✓ រកមើលសាលាដែលសិស្សចង់ដាក់ពាក្យសុំចូលរៀន (ចូលរួមក្នុងពិធីពិព័រណ៍វិទ្យាល័យ ប្រើអ៊ិនធ័រណិត ណាត់ពេលទៅមើលសាលា ប្រើព័ត៌មានដែលលោកអ្នកមានទាំងអស់ ដើម្បីស្វែងយល់អំពីសាលាទាំងនោះ)។

✓ សម្រាប់សាលាដែលយោងទៅលើលក្ខណវិនិច្ឆ័យ (សាលា ឬ កម្មវិធី ទទួលសិស្សដែលមានលក្ខណសម្បត្តិពិសេស ទទួលសិស្សទូទាំងក្រុង) ធ្វើយ៉ាងណា ប្រៀបធៀប តម្រូវការនៃការទទួលសិស្សរបស់សាលា ជាមួយនឹងរបាយការណ៍សិក្សារបស់សិស្ស។

*ការដាក់ពាក្យសុំចូលរៀន*




✓ តាមរយៈទំព័រវ៉ិបសៃរបស់សិស្ស (Student Portal) -អ្នកត្រូវការ អត្តលេខ និង លេខសម្ងាត់ របស់សិស្ស (student's ID number and password)។

✓ តាមរយៈទំព័រវ៉ិបសៃរបស់ មាតាបិតា និងក្រុមគ្រួសារ (Parent & Family Portal) - មាតាបិតាត្រូវការចុះឈ្មោះដើម្បីប្រើវ៉ិបសៃ ទើបអាចចូលបំពេញលិខិតដាក់ពាក្យជ្រើសរើសសាលាបាន។

✓ ស្សានុសិស្ស និងក្រុមគ្រួសារ អាចធ្វើការកែប្រែលិខិតដាក់ពាក្យសុំចូលរៀន រហូតដល់ម៉ោង ៥:០០ ល្ងាច នៃថ្ងៃទី ១៣ ខែវិច្ឆិកា។

✓ **សូមកត់សម្គាល់៖** ក្រសួងអប់រំនឹងប្រើ លិខិតដាក់ពាក្យសុំចូលរៀនរបស់សិស្ស ដែលមានការកែប្រែ **<u>ចុងក្រោយបង្អស់</u>**។

✓ ការជូនដំណឹងទាំងអស់ នឹងបង្ហាញនៅក្នុងទំព័រវ៉ិបសៃរបស់ សិស្ស និង មាតាបិតា រួមទាំងការសម្រេចរបស់សាលា (ព្រមទទួល មិនព្រមទទួល និង ទុកក្នុងបញ្ជីរង់ចាំ)។

*ការផ្តល់ឯកសារគាំទ្រ*



- ✓ បេក្ខជនដាក់ពាក្យសុំចូលរៀនដែលជាសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា **<u>ត្រូវ</u>**សហការជាមួយអ្នកផ្តល់ឱវាទរបស់ពួកគេ ដើម្បីផ្តល់គំរូ តែងសេចក្តី/អត្ថបទ និង/ឬ លិខិតគាំទ្រ បើសិនជាត្រូវការ។
- ✓ បើសិនជាកូនលោកអ្នកមាន IEP, 504 Plan ឬ ចូលរួមក្នុងកម្មវិធី ESOL សូមទាក់ទងទៅអ្នកផ្តល់ឱវាទនៅសាលារបស់កូនលោកអ្នក ដើម្បីពិភាក្សាអំពី វិធីគាំទ្រតាមកម្មវិធី ឡាហ្គៃ (LeGare Advocacy Process)

*ការសួរនាំជាបន្ត*

- ✓ សូមទាក់ទងទៅសាលាដែលមាននៅលើលិខិតដាក់ពាក្យសុំចូលរៀនរបស់អ្នក ដើម្បីស្វែងយល់អំពី ការធ្វើសម្ភាសន៍ ការសម្តែងសាកល្បង និង/ឬ ថ្ងៃខែ និង ម៉ោង ដើរមើលសាលា។

**បើមានសំណួរ?**

សូមទាក់ទងទៅ ការិយាល័យផ្នែក ចុះឈ្មោះ និងចាត់តាំង សិស្ស **តាម**
អ៊ីមែល schoolselect@philasd.org ឬ ទូរស័ព្ទលេខ ២១៥-៤០០-៤២៩០។